**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
លេខ...២៥៥៨/២៦.អ គ រ

ថ្ងៃ ពុធ ៥រោច ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ២០២៦

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការដាក់ដំណើរការមុខងារ Two-Factor Authentication (2FA) ដោយប្រើប្រាស់ One-Time Password (OTP) ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា)

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានកិត្តិយសសូមជម្រាបជូន ប្រតិវេទករ ធុរជន និងវិស័យឯកជនពាក់ព័ន្ធ ដែលមានគណនីប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា) មេត្តាជ្រាបថា មុខងារ Two-Factor Authentication (2FA) ដែលប្រើប្រាស់បច្ចេកវិទ្យាផ្ទៀងផ្ទាត់អត្តសញ្ញាណតាមរយៈកម្មវិធីផ្ទៀងផ្ទាត់អត្តសញ្ញាណបញ្ជរតែមួយជាតិ (NSW Authenticator) ត្រូវបានអភិវឌ្ឍរួចរាល់សម្រាប់ធានាឯកជនភាពនិងសុវត្ថិភាពក្នុងការចូលទៅប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា។

មុខងារ 2FA ក្នុងប្រព័ន្ធអាស៊ីគូដានេះ នឹងត្រូវដាក់ឱ្យដំណើរការចាប់ពី**ថ្ងៃ១៥ ខែឧសភា ឆ្នាំ២០២៦** តទៅ។

ដើម្បីស្វែងយល់បន្ថែមពីរបៀបប្រើប្រាស់ សូមទាញយកសៀវភៅមគ្គុទ្ទេសក៍ តាមរយៈ QR Code ខាងក្រោម។

អាស្រ័យហេតុនេះ សូម ប្រតិវេទករ ធុរជន និងវិស័យឯកជនពាក់ព័ន្ធ មេត្តាជ្រាប និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

សូមស្កេនដើម្បីទាញយកឯកសារ

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីគោរពជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីជ្រាប និងសហការផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
- លោក ណយ សុផាន់ណារិទ្ធ (017 553 055)
- លោក ហេង សុធារិទ្ធ (078 748 222)